# ការលើកលែង

កម្មវិធីជាតិវាស់ស្ទង់សមត្ថភាពសិក្សា – អក្ខរកម្ម និង លេខនព្វន្ត (NAPLAN) គឺជាកម្មវិធីវាស់ស្ទង់សមត្ថភាពសិក្សាមួយសំរាប់សិស្សថ្នាក់ទី 3, ទី 5, ទី 7 និងទី 9 ដោយធ្វើតេស្តតម្រិះវិជ្ជានិងជំនាញនៅក្នុងផ្នែកអក្ខរកម្មនិងលេខនព្វន្ត។

លទ្ធផលនៃតេស្តទាំងនេះផ្តល់ព័ត៌មានទៅឲ្យសិស្ស មាតាបិតា គ្រូបង្រៀន និងនាយកសាលា អំពីលទ្ធផលសំរេចបានរបស់សិស្ស ដែលអាចប្រើដើម្បីជួយដល់ការបង្រៀននិងការរៀនសូត្រ។

ដើម្បីទទួលព័ត៌មានបន្ថែមអំពី NAPLAN សូមអានប័ណ្ណព័ត៌មានសំរាប់មាតាបិតានៅឯ www.vcaa.vic.edu.au ។

នៅក្នុងកាលៈទេសៈជាក់លាក់ សិស្សអាចទទួលការលើកលែងពីការធ្វើតេស្ត NAPLAN ។ នាយកសាលាអាចផ្តល់ការលើកលែងតែចំពោះ៖

**• សិស្សដែលមានពិការភាពបញ្ហា។**

សិស្សដែលមានពិការភាពបញ្ហាខ្លាំងក្លា ដែលធ្វើឲ្យសិស្សនោះមិនអាចធ្វើកិច្ចការនៅក្នុងស្ថានការណ៍ធ្វើតេស្ត អាចទទួលការលើកលែងបាន។ ពិការភាពនេះមានរួមទាំងសិស្សដែលមិនអាចយល់បានទេ ទោះជាមានការណែនាំទូទៅអំពីការធ្វើតេស្តក៏ដោយ។ យ៉ាងណាមិញ សិស្សមិនអាចទទួលការលើកលែងដោយសារតែខ្លួនទទួលលទ្ធផលសិក្សាមិនបានល្អ ឬមានបញ្ហាមិនគោរពវិន័យតែប៉ុណ្ណោះនោះទេ។ សិស្សដែលអាចចូលរួមធ្វើតេស្តនៅក្រោមលក្ខខណ្ឌពិសេស គួរធ្វើតេស្តដើម្បីវាស់ស្ទង់សមត្ថភាពសិក្សា។ ដើម្បីទទួលព័ត៌មានបន្ថែមអំពីលក្ខណ្ឌពិសេសទាំងឡាយ សូមពិភាក្សាបញ្ហានេះជាមួយសាលារៀនរបស់កូនលោកអ្នក។

**• សិស្សដែលបានកំពុងរៀនអង់គ្លេសរយៈពេលតិចជាងមួយឆ្នាំ។**

សិស្សមកពីបរទេសដែលបានមកដល់ប្រទេសអូស្រ្តាលីនៅពេលតិចជាងមួយឆ្នាំនៅមុនពេលធ្វើតេស្ត ហើយដែលមានសាវតារភាសាក្រៅពីអង់គ្លេស អាចទទួលការលើកលែងបាន។

សិស្សដែលទទួលការលើកលែងពីការធ្វើតេស្ត NAPLAN នឹងត្រូវបានរាយការណ៍ថាបានទទួលលទ្ធផលទាបជាងស្តង់ដារគំនូសសំគាល់ជាតិ សំរាប់គោលបំណងនៃការរាយការណ៍ជូនក្រុមប្រឹក្សាក្រសួងសិក្សាអប់រំ ការងារ បណ្តុះ បណ្តាល និងកិច្ចការយុវជន (MCEETYA) ។

សិស្សដែលមិនចូលរួមក្នុងការធ្វើតេស្ត NAPLAN ដោយសារតែមូលហេតុក្រៅអំពីចំណុចទាំងឡាយដែលបានលើកឡើងនៅខាងលើ មិនគួរត្រូវបានកត់ត្រាថាជាសិស្សលើកលែងទេ។

នាយកសាលា និងមាតាឬបិតា ឬអាណាព្យាបាល ត្រូវចុះហត្ថលេខាលើក្រដាសបំពេញកំណត់ត្រានៃការលើកលែងសំរាប់សិស្សលើកលែងនីមួយៗ។

សិស្សលើកលែងដែលមិនបានចូលរួមនៅថ្ងៃធ្វើតេស្ត នឹងត្រូវបានរាយការណ៍ថាជាសិស្ស**លើកលែង** មិនមែនថាជាសិស្ស **អវត្តមាន**ឡើយ។